ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៣៧..អសណ. ក២៥

# សេចក្តីថ្លែងហេតុ
# នៃសេចក្តីព្រាងច្បាប់
# ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣

## I. សេចក្តីផ្តើម

*១-សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣ ត្រូវបានរៀបចំក្នុងបរិការណ៍ដែលសេដ្ឋកិច្ចកម្ពុជាបានងើបចេញពីវិបត្តិសេដ្ឋកិច្ចសកលលោកយ៉ាងឆាប់រហ័ស ហើយបាន និងកំពុងបង្ហាញនូវភាពមាំមួនឆ្ពោះទៅរកគោលដៅគោលនយោបាយកំណើនប្រចាំឆ្នាំ៧%របស់រាជរដ្ឋាភិបាល ទោះជាស្ថិតក្នុងលក្ខណៈផុយស្រួយនិងហានិភ័យខ្ពស់នៅឡើយក៏ដោយ។* ជាក់ស្តែង ការងើបឡើងវិញយ៉ាងឆាប់រហ័សនិងរឹងមាំនៃសេដ្ឋកិច្ចកម្ពុជាក្រោយវិបត្តិសេដ្ឋកិច្ចសកលលោកដែលសម្រេចបាន៦%នៅឆ្នាំ២០១០និង៧,១%នៅឆ្នាំ២០១១ ហើយត្រូវបានព្យាករថានឹងសម្រេចបានប្រមាណ៧%នៅឆ្នាំ២០១២នេះ បានធ្វើឲ្យកំណើនសេដ្ឋកិច្ចមធ្យមប្រចាំឆ្នាំក្រោយវិបត្តិ(២០១០-២០១២) សម្រេចបាន៦,៧%។ លទ្ធផលនេះបានមកពីកំណើនមធ្យមប្រចាំឆ្នាំនៃវិស័យកសិកម្មចំនួន៣,២% វិស័យឧស្សាហកម្មចំនួន១៣,៣%និងវិស័យសេវាកម្មចំនួន៥%។ កំណើននៃវិស័យកសិកម្មភាគច្រើនដោយសារការបន្តកើនឡើងនៃដំណាំស្រូវ កៅស៊ូនិងបណ្តាដំណាំដែលកំពុងមានសក្តានុពលនៅលើទីផ្សារដទៃទៀតដូចជាពោត សណ្តែកនិងដំឡូងមីជាដើម។ រីឯកំណើននៃវិស័យឧស្សាហកម្មភាគច្រើនដោយសារការបន្តកើនឡើងនៃផ្នែកវាយនភណ្ឌ ការកែច្នៃ សំណង់ និងអគ្គិសនី។ ដោយឡែកកំណើននៃវិស័យសេវាកម្មគឺភាគច្រើនបានមកពីការបន្តមានកំណើននៃវិស័យទេសចរណ៍ ហិរញ្ញវត្ថុនិងធនាគារ អចលនវត្ថុនិងពាណិជ្ជកម្ម ព្រមទាំងការដឹកជញ្ជូននិងទូរគមនាគមន៍។ ទោះជាយ៉ាងណា ស្ថានភាពសេដ្ឋកិច្ចចុងឆ្នាំ២០១២និងឆ្នាំ២០១៣ខាងមុខនេះ នឹងនៅតែបន្តមានហានិភ័យខ្ពស់នៅឡើយ ដោយសារស្ថានភាពវិបត្តិបំណុលនៅអឺរ៉ុបនៅតែបន្តនិងការងើបឡើងវិញដ៏យឺតនៃសេដ្ឋកិច្ចអាមេរិកនៅតែពុំទាន់មានភាពប្រាកដប្រជា ដែលបាននិងកំពុងមិនត្រឹមតែបន្តធ្វើឲ្យមានការថមថយនៃតម្រូវការទីផ្សារសម្រាប់អាស៊ីប៉ុណ្ណោះទេ តែថែមទាំងកំពុងមានសញ្ញាណធ្លាក់ចុះនៃការនាំចេញនិងនាំចូលនៅក្នុងតំបន់អាស៊ីថែមទៀតផង។ ដូច្នេះ ដោយសារពិពិធកម្មសេដ្ឋកិច្ចកម្ពុជាពុំទាន់ពង្រីកបានមូលដ្ឋានរបស់ខ្លួននៅឡើយនិងការពឹងផ្អែកខ្លាំងលើទីផ្សារខាងក្រៅ ព្រមទាំងការរីកចម្រើននៃទីផ្សារហិរញ្ញវត្ថុនិងធនាគារនៅទាប ធ្វើឲ្យសេដ្ឋកិច្ចកម្ពុជាងាយរងគ្រោះពីវិបត្តិសេដ្ឋកិច្ចសកល

លោក និងប្រឈមនឹងវដ្តធុរកិច្ចដែលមានការលំបាកក្នុងការពង្រីកមូលដ្ឋាននិងបង្កើនការវិនិយោគ។ ប៉ុន្តែស្ថិតក្នុងសមោកាសនេះ សេដ្ឋកិច្ចកម្ពុជាក៏ពុំសូវរងនូវផលប៉ះពាល់ដោយផ្ទាល់ពីវិបត្តិហិរញ្ញវត្ថុសកលលោកដែរ។

២-*កន្លងទៅ រាជរដ្ឋាភិបាលមិនត្រឹមតែរក្សាបាននូវស្ថិរភាពនយោបាយ ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ស្ថិរភាពហិរញ្ញវត្ថុ និងរក្សាបាននូវអធិបតេយ្យ បូរណភាពទឹកដី សន្តិសុខ និងសុវត្ថិភាពសង្គម នៅក្នុងពេលនិងក្រោយពេលមានវិបត្តិកលិយុគសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសកលលោក ព្រមទាំងវិបត្តិព្រំដែនកម្ពុជា-ថៃ និងគ្រោះទឹកជំនន់ប៉ុណ្ណោះទេ តែថែមទាំងនាំមកនូវកេរ្តិ៍ឈ្មោះដែលកម្ពុជាត្រូវបានវាយតម្លៃថាជាប្រទេសទី១៥លើពិភពលោកដែលសម្រេចបានកំណើនសេដ្ឋកិច្ចខ្ពស់ក្នុងរយៈពេល១០ឆ្នាំចុងក្រោយ ជាប្រទេសទី៥ក្នុងចំណោមប្រទេសកំពុងអភិវឌ្ឍដែលអាចនឹងសម្រេចបាននូវគោលដៅអភិវឌ្ឍសហស្សវត្សរ៍ និងស្ថិតក្នុងចំណាត់ថ្នាក់ទី១នៅអាស៊ីប៉ាស៊ីហ្វិកដែលសម្រេចបាននូវវឌ្ឍនភាពល្អប្រសើរក្នុងការកែលម្អសូចនាករផ្នែកសង្គមកិច្ច។* លទ្ធផលនេះ មិនមែនបានមកដោយចៃដន្យឬដោយសារតែការហ៊ានបង់ថ្លៃនោះទេ គឺពិតជាបានមកដោយសារការដឹកនាំដ៏ត្រឹមត្រូវប្រកបដោយឆន្ទៈនយោបាយមោះមុត ឈ្លាសវៃនិងភ្លឺស្វាងរបស់រាជរដ្ឋាភិបាល ជាមួយនឹងការដាក់ចេញនូវគោលនយោបាយនិងយុទ្ធសាស្ត្រត្រឹមត្រូវ ច្បាស់លាស់ និងសមស្រប ព្រមទាំងមានរចនាសម្ព័ន្ធនិងវិធីសាស្ត្រគ្រប់គ្រងប្រកបដោយភាពសក្តិសិទ្ធិនិងប្រសិទ្ធភាពខ្ពស់។ ជាក់ស្តែង ការអនុវត្តគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចដ៏ត្រឹមត្រូវនិងគោលនយោបាយហិរញ្ញវត្ថុសាធារណៈដោយប្រយ័ត្នប្រយែងគួបផ្សំនឹងគោលនយោបាយរូបិយវត្ថុសមស្រប ព្រមទាំងការជំរុញការអនុវត្តគោលនយោបាយនិងកម្មវិធីកែទម្រង់សំខាន់ៗ និងចាំបាច់រួមទាំងការដាក់ចេញនូវវិធានការ បទបញ្ជានិងសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលប្រកបដោយភាពសក្តិសិទ្ធិ ប្រសិទ្ធភាពនិងទាន់ពេលវេលា បានធ្វើឲ្យកម្ពុជាមិនត្រឹមតែអាចចេញផុតពីវិបត្តិយ៉ាងឆាប់រហ័សប៉ុណ្ណោះទេ តែថែមទាំងសម្រេចបាននូវអត្រាកំណើនខ្ពស់ រក្សាបានស្ថិរភាពជាសារវន្តនៃអតិផរណានិងអត្រាប្តូរប្រាក់ ព្រមទាំងកសាងបាននូវហេដ្ឋារចនាសម្ព័ន្ធទាំងផ្នែករឹងទាំងផ្នែកទន់ដែលជាមូលដ្ឋានសម្រាប់ពង្រឹងនិងពង្រីកសកម្មភាពសេដ្ឋកិច្ច បង្កើនចំណូលនិងលើកកម្ពស់សេវាសាធារណៈជូនប្រជាពលរដ្ឋ ហើយសម្រេចបាននូវការកាត់បន្ថយភាពក្រីក្រក្នុងអត្រាជាង១%ក្នុងមួយឆ្នាំស្របតាមគោលដៅនៃ**យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២**ទៀតផង។ លើសពីនេះទៅទៀត គឺដោយសារការផ្តល់ទំនុកចិត្តនិងជំនឿរបស់ប្រជាពលរដ្ឋមកលើការដឹកនាំនិងការគ្រប់គ្រង ព្រមទាំងការប្តេជ្ញាដ៏មោះមុតនិងហ៊ានពុះពារគ្រប់ឧបសគ្គរបស់រាជរដ្ឋាភិបាលក្នុងការការពារនិងកសាងមាតុភូមិ ការពារផលប្រយោជន៍ប្រជាពលរដ្ឋ ក្នុងគោលដៅឆ្ពោះទៅរកអនាគតមួយដ៏រុងរឿងនិងភ្លឺស្វាងស្របតាមឆន្ទៈនិងបំណងប្រាថ្នារបស់ប្រជាជាតិទាំងមូល ដែលវាក៏ត្រូវបានឆ្លុះបញ្ចាំងតាមរយៈលទ្ធផលចុងក្រោយនៃការស្ទង់មតិប្រជាពលរដ្ឋថាប្រជាពលរដ្ឋជាង៧០ភាគរយយល់ថារាជរដ្ឋាភិបាលបាននិងកំពុងដើរលើផ្លូវត្រូវ។

៣- *សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣នេះគឺពិតជាឧបករណ៍គោលនយោបាយដ៏មានសារៈសំខាន់បំផុត ដើម្បីអនុញ្ញាតឲ្យរាជរដ្ឋាភិបាលបន្តអនុវត្តបញ្ចប់* **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម២០០៩-២០១៣** *និង* **យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២** *សំដៅឈានទៅសម្រេចឲ្យបាននូវ* **របៀបវារៈគោលនយោបាយសង្គម-សេដ្ឋកិច្ច** *នៃ* **កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៤**។ សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣នេះ នឹងបន្តបង្កនូវកត្តាជាបុព្វបទទាំងឡាយ សម្រាប់ការឈានទៅសម្រេចឲ្យបាននូវគោលនយោបាយជាមូលដ្ឋានគ្រឹះខាងសេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាលនោះគឺ *ការធានាឲ្យបាននូវកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាពក្នុងអត្រាប្រមាណ៧%ក្នុងមួយឆ្នាំ នៅលើមូលដ្ឋានទូលាយជាងមុន និងមានសមត្ថភាពប្រកួតប្រជែងជាងមុន នៅក្នុងបរិការណ៍អត្រាអតិផរណាទាបក្នុងកម្រិតតួលេខមួយខ្ទង់* និង *ការធានាសម្រេចឲ្យបាននូវការកាត់បន្ថយអត្រានៃភាពក្រីក្រឲ្យបានលើស១%ក្នុងមួយឆ្នាំនិងការធានាកែលម្អសូចនាករសំខាន់ៗក្នុងវិស័យសង្គមកិច្ច ជាពិសេសក្នុងវិស័យអប់រំ សុខាភិបាល និងសមភាពយេនឌ័រ*។ ជាក់ស្តែងច្បាប់នេះនឹងអនុញ្ញាតឲ្យរាជរដ្ឋាភិបាលបាន (១)បន្តអនុវត្តគោលបំណងគោលនយោបាយ កម្មវិធី យុទ្ធសាស្ត្រ និងបណ្តាសកម្មភាពការងារអាទិភាពតាមវិស័យ ពិសេសបន្តជំរុញការអនុវត្តគោលនយោបាយជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ ការបន្តកសាងនិងកែលម្អហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ពិសេសហេដ្ឋារចនាសម្ព័ន្ធដែលត្រូវបានខូចខាតដោយទឹកជំនន់ ការបន្តពង្រឹងនិងពង្រីកផ្នែកឧស្សាហកម្មកាត់ដេរ និងផ្នែកសេវាកម្មទេសចរណ៍ ព្រមទាំងការបន្តជំរុញការអភិវឌ្ឍវិស័យឯកជន ធនាគារ និងទីផ្សារហិរញ្ញវត្ថុ(២)បន្តអនុវត្តកម្មវិធីកែទម្រង់សំខាន់ៗនិងចាំបាច់ដូចជាកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កម្មវិធីវិមជ្ឈការនិងវិសហមជ្ឈការ កំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់ការគ្រប់គ្រងដីធ្លី កំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ កំណែទម្រង់កងកម្លាំងប្រដាប់អាវុធ ការពង្រឹងអភិបាលកិច្ចល្អនិងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ (៣)ព្រមទាំងធានាដល់ការរៀបចំបោះឆ្នោតតំណាងរាស្ត្រ ដែលសុទ្ធសឹងតែជាការងារសំខាន់និងចាំបាច់សម្រាប់បន្តពង្រឹងការអនុវត្តលទ្ធិប្រជាធិបតេយ្យ រក្សាឲ្យបាននូវស្ថិរភាពនយោបាយស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរក្សាបាននូវសន្តិភាពនិងសុវត្ថិភាពសង្គម ការពារបាននូវអធិបតេយ្យនិងបូរណភាពទឹកដី ធានាបានកំណើនសេដ្ឋកិច្ចខ្ពស់និងប្រកបដោយចីរភាព ព្រមទាំងបង្កើនបាននូវភាពសក្តិសិទ្ធិ ប្រសិទ្ធភាពនិងគុណភាពសេវាសាធារណៈជូនប្រជាពលរដ្ឋឲ្យបានកាន់តែប្រសើរឡើង ក្នុងគោលដៅសម្រេចឲ្យបាននូវភាពសុខដុមរមនាសង្គមនិងសុខុមាលភាពរបស់ប្រជាពលរដ្ឋ។

៤- *ឆ្នាំ២០១១(កំណើន៧,១%)កន្លងទៅគឺជាឆ្នាំដែលសេដ្ឋកិច្ចកម្ពុជាបានបន្តហក់ឡើងបន្ទាប់ពីបានងើបឡើងវិញយ៉ាងឆាប់រហ័សនៅក្នុងឆ្នាំ២០១០(កំណើន៦%) ដោយសារការបន្តកើនឡើងវិញនៃផ្នែកឧស្សាហកម្មកាត់ដេរនិងផ្នែកសេវាកម្មទេសចរណ៍ ទោះជាផ្នែកឧស្សាហកម្មសំណង់និងសេវាកម្មអចលនទ្រព្យនៅទ្រឹងក៏ដោយ។ ការអនុវត្តថវិកាឆ្នាំ២០១១ បានកាត់បន្ថយឱនភាពថវិកាសរុប០,៣៣%នៃផ.ស.ស. ប៉ុន្តែឱនភាពថវិកាសរុបនៅតែមានកម្រិតខ្ពស់(-៨,១៦%) ដោយសារ*

*កំណើនចំណូលនៅមានកម្រិតទាបជាងមុនវិបត្តិ ហើយថែមទាំងមានតម្រូវការចំណាយលើគ្រោះទឹកជំនន់ថែមទៀតនិងទំនាស់ព្រំដែនក៏ពុំទាន់ធូរស្រាលនៅឡើយ។* បន្ទាប់ពីបានចេញផុតពីវិបត្តិយ៉ាងឆាប់រហ័ស កម្ពុជាសម្រេចបាននូវអត្រាកំណើនខ្ពស់ក្នុងឆ្នាំ២០១១ គឺ៧,១% ធៀបនឹង៦%គ្រោងនៅក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១១។ កំណើននេះបានមកដោយសារកំណើនវិស័យកសិកម្មចំនួន៣,១% វិស័យឧស្សាហកម្មចំនួន១៤,៥% ក្នុងនោះ ផ្នែកវាយនភណ្ឌកើន១៩,៩% និងវិស័យសេវាកម្មចំនួន៥% ក្នុងនោះផ្នែកទេសចរណ៍កើន៦,៦%។ អត្រាអតិផរណាមធ្យមប្រចាំឆ្នាំមានប្រមាណ៥,៥% និងអត្រាប្តូរប្រាក់មានស្ថិរភាពក្នុងរង្វង់៤ ០៧៦រៀល ក្នុងមួយដុល្លារអាមេរិក។ ចំណូលក្នុងប្រទេសបានកើនឡើងត្រឹម៨,៣% ធៀបនឹងការអនុវត្តឆ្នាំ២០១០ ហើយអនុវត្តបានទាបជាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១១ ប្រមាណ១,៨% ដោយសារការអនុវត្តបានទាបនៃចំណូលពន្ធដារនិងចំណូលមិនមែនសារពើពន្ធ។ ទោះជាមានការថយចុះនៃចំណាយសរុបថវិការដ្ឋប្រមាណ០,៦១%នៃផ.ស.ស. ធៀបនឹងឆ្នាំ២០១០ ប៉ុន្តែចំណាយនេះនៅតែមានកម្រិតខ្ពស់ដោយសារតែមានតម្រូវការចំណាយសម្រាប់សង្គ្រោះនិងស្តារហេដ្ឋារចនាសម្ព័ន្ធដែលរងគ្រោះដោយទឹកជំនន់បន្ថែមលើចំណាយការពារអធិបតេយ្យដែលត្រូវបន្ត។ ទោះជាយ៉ាងណា ចំណាយទាំងនេះ គឺសុទ្ធសឹងជាចំណាយដែលមានសារៈសំខាន់និងចាំបាច់ ហើយរាជរដ្ឋាភិបាលពិតជាបានរក្សាយ៉ាងខ្ជាប់ខ្ជួននូវវិន័យថវិកា ដោយត្បិតត្បៀតចំណាយចរន្តដើម្បីរក្សាអតិរេកចរន្តសម្រាប់ការវិនិយោគសាធារណៈ និងខិតខំកៀរគរហិរញ្ញប្បទានឥតសំណងនិងកម្ចីសម្បទាន ក្នុងគោលដៅទាញយកឱកាសដែលកម្ពុជានៅស្ថិតក្នុងក្របខ័ណ្ឌនៃប្រទេសដែលអាចទទួលហិរញ្ញប្បទានឥតសំណងនិងកម្ចីសម្បទាន ព្រមទាំងរក្សានូវប្រសិទ្ធភាពវិនិយោគ និងធានាបានការគ្រប់គ្រងបំណុលប្រកបដោយប្រសិទ្ធភាព។

៥- *កំណើនសេដ្ឋកិច្ចឆ្នាំ២០១២ ត្រូវបានព្យាករថាអាចនឹងសម្រេចបាន៧% ទោះជាស្ថានភាពវិបត្តិបំណុលនៅអឺរ៉ុប និងភាពមិនប្រាកដប្រជានៃការងើបឡើងវិញនៃសេដ្ឋកិច្ចអាមេរិកនៅតែបន្តគំរាមកំហែងដល់ទីផ្សារសេដ្ឋកិច្ចកម្ពុជា ពិសេស ទីផ្សារវាយនភណ្ឌនិងទេសចរណ៍ ព្រមទាំងការធ្លាក់ចុះថ្លៃកសិផលនាំចេញមួយចំនួនក៏ដោយ។ ជារួមការអនុវត្តថវិកាឆ្នាំ២០១២ នឹងមានលក្ខណៈល្អប្រសើរជាងឆ្នាំ២០១១ ដែលតាមការព្យាករឱនភាពថវិកាសរុបនឹងធ្លាក់មកនៅត្រឹម-៥,៧៩%នៃផ.ស.ស. ធៀបនឹង-៨,១៦%នៅឆ្នាំ២០១១ ដោយសារការត្បិតត្បៀតចំណាយចរន្តនិងកំណើនចំណូលក្នុងស្រុកដែលធ្វើឱ្យអតិរេកចរន្តមានកំណើន០,៥៥%នៃផ.ស.ស.។* តាមការព្យាករចុងក្រោយ កំណើនសេដ្ឋកិច្ចឆ្នាំ២០១២អាចនឹងសម្រេចបានខ្ពស់ជាង៦,៥% ដែលបានគ្រោងនៅក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១២ ដោយសារតែផ្នែកឧស្សាហកម្មកាត់ដេរនិងផ្នែកសេវាកម្មទេសចរណ៍បាននិងកំពុងបន្តកើនឡើងគួរឲ្យកត់សម្គាល់។ តាមការគណនាវិស័យកសិកម្មនឹងមានកំណើន២,៤% វិស័យឧស្សាហកម្មនឹងមានកំណើន១១,៨% ក្នុងនោះផ្នែកវាយនភណ្ឌនឹងកើន១៤,៥% និងវិស័យសេវាកម្មនឹងមានកំណើន៦,៨% ដែលក្នុងនោះ ផ្នែកសេវាកម្មទេសចរណ៍នឹងកើនប្រមាណ៧%។ រាជរដ្ឋាភិបាលនឹងបន្តខិតខំជំរុញបន្ថែមទៀតលើការអភិវឌ្ឍវិស័យឯកជន វិស័យហិរញ្ញវត្ថុនិងធនាគារ ទេសចរណ៍

សកម្មភាពសំណង់និងសេវាកម្ម ដើម្បីជំរុញកំណើន ពិសេសការបន្តធ្វើពិពិធកម្មសេដ្ឋកិច្ច ដោយផ្តោតការយកចិត្តទុកដាក់លើការជំរុញវិស័យកសិកម្ម កសិឧស្សាហកម្ម ព្រមទាំងការពង្រឹងនិងពង្រីកការកែលម្អហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ពិសេសប្រព័ន្ធស្រោចស្រព។ លើសពីនេះ រាជរដ្ឋាភិបាលនឹងបន្តពង្រឹងការអនុវត្តគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈប្រកបដោយភាពត្រឹមត្រូវ ម៉ឺងម៉ាត់និងប្រុងប្រយ័ត្នខ្ពស់ គួបផ្សំជាមួយនឹងការជំរុញការកែលម្អការពង្រឹងការប្រមូលនិងការគ្រប់គ្រងចំណូលការកែលម្អនិងការពង្រឹងការអនុវត្តនិងការគ្រប់គ្រងចំណាយ ក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ព្រមទាំងការធ្វើវិចារណកម្មចំណាយសមស្រប ដើម្បីធានាឲ្យការអនុវត្តថវិកាឆ្នាំ២០១២ សម្រេចបានលទ្ធផលល្អ។តាមការគណនាចំណូលក្នុងស្រុក ថវិការដ្ឋសរុបអាចនឹងសម្រេចបានលើសច្បាប់ប្រមាណ៣,២% ស្មើនឹង១៣,៨៥%នៃផ.ស.ស. ដែលក្នុងនោះ ចំណូលសារពើពន្ធថវិការដ្ឋនឹងសម្រេចបានលើសច្បាប់ប្រមាណ១% ស្មើនឹង១១,៥៨%នៃផ.ស.ស. (ក្នុងនោះចំណូលគយនិងរដ្ឋាករ ស្មើនឹង៦,១១% និងចំណូលពន្ធដារស្មើនឹង៤,៥៨%) ចំណូលមិនមែនសារពើពន្ធនឹងសម្រេចបានលើសច្បាប់ប្រមាណ១៣,៥% ស្មើនឹង២,០៦%នៃផ.ស.ស.។ ដោយឡែក ចំណាយថវិការដ្ឋសរុបអាចនឹងអនុវត្តលើសច្បាប់ប្រមាណ១,៦% ស្មើនឹង១៩,៦៤%នៃផ.ស.ស.តែថយចុះ១,៣៨%នៃផ.ស.ស. ធៀបនឹងការអនុវត្តឆ្នាំ២០១១ ដែលក្នុងនោះ ចំណាយចរន្តថវិការដ្ឋសរុបនឹងអនុវត្តលើសច្បាប់ប្រមាណ២,៧% ស្មើនឹង១១,៧៧%នៃផ.ស.ស. គឺកើនឡើង០,៣៩%នៃផ.ស.ស. ធៀបនឹងការអនុវត្តឆ្នាំ២០១១ និងចំណាយមូលធនថវិការដ្ឋសរុបនឹងសម្រេចបានតាមច្បាប់គឺស្មើនឹង៧,៨៧%នៃផ.ស.ស.គឺថយចុះ១,៧៧%នៃផ.ស.ស. ធៀបនឹងការអនុវត្តឆ្នាំ២០១១ ដែលក្នុងនោះ ហិរញ្ញប្បទានក្នុងប្រទេសសរុបស្មើនឹង២,៩០%នៃផ.ស.ស. គឺថយចុះ០,២០%នៃផ.ស.ស. ធៀបនឹងការអនុវត្តឆ្នាំ២០១១ និងហិរញ្ញប្បទានក្រៅប្រទេសស្មើនឹង៤,៩៨%នៃផ.ស.ស. គឺថយចុះ១,៥៥%នៃផ.ស.ស. ធៀបនឹងការអនុវត្តឆ្នាំ២០១១។ ការអនុវត្តចំណូលចំណាយនេះ អាចនឹងធ្វើឲ្យមានអតិរេកចរន្តប្រមាណ១,៨៨%នៃផ.ស.ស. និងឱនភាពថវិកាសរុបប្រមាណ-៥,៧៩%នៃផ.ស.ស. គឺថយចុះ២,៣៧%នៃផ.ស.ស. ធៀបនឹងការអនុវត្តឆ្នាំ ២០១១។

## II. គោលនយោបាយនិងក្របខ័ណ្ឌថវិកាឆ្នាំ២០១៣

៦-*ការរៀបចំថវិកាឆ្នាំ២០១៣ គឺពិតជាស្ថិតក្នុងបរិកាលណ៍ដែលសេដ្ឋកិច្ចកម្ពុជាបានងើបចេញពីវិបត្តិសេដ្ឋកិច្ចសកលលោកយ៉ាងឆាប់រហ័ស ហើយបាននិងកំពុងបង្ហាញនូវភាពមាំមួនឆ្ពោះទៅរកគោលដៅគោលនយោបាយកំណើនប្រចាំឆ្នាំ៧% របស់រាជរដ្ឋាភិបាល ប៉ុន្តែស្ថានភាពសេដ្ឋកិច្ចកម្ពុជាស្ថិតក្នុងលក្ខណៈផុយស្រួយនិងមានហានិភ័យខ្ពស់នៅឡើយ ដែលទាមទារឲ្យមានការប្រុងប្រយ័ត្នខ្ពស់។ ទោះជាយ៉ាងណាក្នុងរយៈពេលមធ្យម(២០១៣- ២០១៨) កំណើនសេដ្ឋកិច្ចកម្ពុជានៅតែអាចនឹងសម្រេចបានក្នុងកម្រិត៧% តាមគោលដៅចក្ខុវិស័យរបស់រាជរដ្ឋាភិបាល។* ផ្អែកលើមូលដ្ឋាននៃក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចនិងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ពិសេសផ្អែកលើលទ្ធផលនៃការអនុវត្តឆ្នាំ២០១១ និងការគណនាសម្រាប់ឆ្នាំ២០១២ ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈសម្រាប់ឆ្នាំ២០១៣ ត្រូវបានកំណត់ជាសូចនាករសំខាន់ៗ ដូចខាងក្រោម៖

• កំណើនសេដ្ឋកិច្ចតាមថ្លៃថេរនឹងសម្រេចបានប្រមាណ៧% ដែលធ្វើឲ្យផលិតផលក្នុងស្រុកសរុប(ផ.ស.ស.) គិតជាទឹកប្រាក់តាមថ្លៃបច្ចុប្បន្នមានចំនួន៦៣ ២៤០ ០០០លានរៀល ដែលត្រូវជាប្រមាណ១៥ ៦១៥លានដុល្លារអាមេរិក។ ដូច្នេះ នៅឆ្នាំ២០១៣ ផលិតផលក្នុងស្រុកសរុបសម្រាប់មនុស្សម្នាក់ អាចនឹងឡើងលើសពី១ ០០០ដុល្លារអាមេរិក ហើយកម្ពុជាអាចនឹងចេញផុតពីចំណាត់ថ្នាក់ជាប្រទេសមានចំណូលទាប ក្លាយទៅជាប្រទេសមានចំណូលមធ្យមកម្រិតទាបក្នុងពេលឆាប់ៗខាងមុខ។

• អតិផរណានឹងរក្សាឲ្យស្ថិតក្នុងរង្វង់៥% ដោយរាជរដ្ឋាភិបាលត្រូវអនុវត្តគោលនយោបាយហិរញ្ញវត្ថុសាធារណៈនិងគោលនយោបាយរូបិយវត្ថុសមស្របនិងប្រុងប្រយ័ត្ន។

• អត្រាប្តូរប្រាក់រៀលដុល្លារអាមេរិកនឹងរក្សាឲ្យស្ថិតក្នុងរង្វង់ ៤ ០៥០រៀលក្នុង១ដុល្លារអាមេរិក។

• ឱនភាពពាណិជ្ជកម្មនឹងថយចុះពី-៩,១%នៃផ.ស.ស.ក្នុងឆ្នាំ២០១២មក-៨,៣%នៃផ.ស.ស. ក្នុងឆ្នាំ២០១៣ ដោយសារកំណើននៃការនាំចេញខ្ពស់ជាងកំណើននៃការនាំចូល ដែលធ្វើឲ្យកម្ពុជាឈានទៅរក្សាបាននូវតុល្យភាពនៃជញ្ជីងពាណិជ្ជកម្មក្នុងកម្រិតសមស្រប។

• ឱនភាពថវិកាសរុបនឹងថយចុះពី-៥,៧៩%នៃផ.ស.ស.ក្នុងឆ្នាំ២០១២មក-៥,៦០%នៃផ.ស.ស.ក្នុងឆ្នាំ២០១៣ និងអនុវត្តគោលនយោបាយកាត់បន្ថយឱនភាពថវិកាសរុបជាបណ្តើរៗទៅរកកម្រិតដែលមាននិរន្តរភាពថវិកាគឺ-៣%នៃផ.ស.ស. និងសន្សំអតិរេកសាច់ប្រាក់ឡើងវិញដូចមុនវិបត្តិឆ្នាំ២០០៩ ដើម្បីបង្កើនទុនបម្រុងរបស់រដ្ឋសម្រាប់ត្រៀមទប់ទល់វិបត្តិនិងហានិភ័យដែលអាចកើតឡើងជាយថាហេតុ។

៧-*ផ្អែកលើមូលដ្ឋាននៃ* ***យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២*** *និង* ***ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម២០០៩-២០១៣*** *ជាពិសេស ដើម្បីបម្រើឲ្យការអនុវត្តគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច គោលនយោបាយអាទិភាពតាមវិស័យនិងផែនការសកម្មភាពរបស់រាជរដ្ឋាភិបាលក្នុងការសម្រេចឲ្យបានតាមគោលដៅនៃ* ***របៀបវារៈគោលនយោបាយសង្គម-សេដ្ឋកិច្ច*** *នៃ* ***កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៤*** *ថវិកាឆ្នាំ២០១៣ មានគោលដៅសំខាន់ៗដូចតទៅ៖*

• បន្តអនុវត្តគោលបំណងគោលនយោបាយ កម្មវិធី យុទ្ធសាស្ត្រ និងបណ្តាសកម្មភាពការងារអាទិភាពតាមវិស័យ ពិសេសបន្តជំរុញការអនុវត្តគោលនយោបាយជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ ព្រមជាមួយនឹងកសិផលឯទៀតដូចជាកៅស៊ូនិងដំឡូងមី បន្តកសាងនិងកែលម្អហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ពិសេសហេដ្ឋារចនាសម្ព័ន្ធរូបវន្តដែលបានខូចខាតដោយទឹកជំនន់ បន្តពង្រឹងនិងពង្រីកផ្នែកឧស្សាហកម្មកាត់ដេរនិងផ្នែកសេវាកម្មទេសចរណ៍ ព្រមទាំងបន្តជំរុញការអភិវឌ្ឍវិស័យឯកជន ធនាគារ និងទីផ្សារហិរញ្ញវត្ថុ។

• បន្តអនុវត្តគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចគាំទ្រកំណើននិងកម្មវិធីវិនិយោគសាធារណៈរំកិល៣ឆ្នាំ២០១៣-២០១៥ ដើម្បីរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចនិងជំរុញកំណើនប្រកបដោយចីរភាព។

• បន្តផ្តល់អាទិភាពដល់ការបង្កើននិងលើកកម្ពស់គុណភាពសេវាកម្មនៅក្នុងវិស័យសង្គមកិច្ច ជាពិសេស វិស័យអប់រំ សុខាភិបាល ការកសាងធនធានមនុស្ស និងសំណាញ់សុវត្ថិភាពសង្គម រួម

ទាំងការបន្តអនុវត្តគោលនយោបាយផ្តល់ដីសម្បទានសង្គមកិច្ចដល់គ្រួសារអតីតកងកម្លាំងប្រដាប់អាវុធ និងការបន្តជំរុញការអនុវត្តសកម្មភាពថ្មីលើគោលនយោបាយចាស់នៃកំណែទម្រង់ការគ្រប់គ្រងដីធ្លី។

- ធានាដល់ការរៀបចំការបោះឆ្នោតតំណាងរាស្ត្រនិងការបន្តជំរុញការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីបន្តពង្រឹងនិងពង្រីកការអនុវត្តលទ្ធិប្រជាធិបតេយ្យ និងនីតិរដ្ឋនៅកម្ពុជា។

- ធានាបម្រើឲ្យការបន្តសកម្មភាពកែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាលលើគ្រប់ផ្នែក រួមមានកំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ កំណែទម្រង់ការគ្រប់គ្រងដីធ្លី កំណែទម្រង់កងកម្លាំងប្រដាប់អាវុធ ការអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍថ្នាក់ក្រោមជាតិតាមបែបប្រជាធិបតេយ្យនិងការប្រយុទ្ធប្រឆាំងអំពើពុករលួយ ដើម្បីបន្តពង្រឹងអភិបាលកិច្ចល្អនិងការបង្កើនភាពសក្តិសិទ្ធិនិងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ។

*៨-ដើម្បីអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ និងកម្មវិធីសកម្មភាពអាទិភាពរបស់រាជរដ្ឋាភិបាលដែលបានកំណត់ខាងលើ ក្នុងគោលដៅសម្រេចឲ្យបានតាម* **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម២០០៩-២០១៣** *ក៏ដូចជា* **យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២** *ពិសេសគោលដៅនៃ* **"របៀបវារៈគោលនយោបាយសង្គម-សេដ្ឋកិច្ច"** *នៃ* **"កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៤"** *ឆ្នាំ២០១៣ រាជរដ្ឋាភិបាលនឹងត្រូវការថវិកាចំណាយសរុបចំនួន១២ ៥២៧ ០០៨លានរៀល កើនឡើង១២,៩% ស្មើនឹង១៩,៨១%នៃផ.ស.ស. គឺកើនឡើង០,៤៨%នៃផ.ស.ស.ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១២* ។ ចំណាយថវិការដ្ឋឆ្លងរតនាគារជាតិមានចំនួន៩ ៣៨១ ០០៨លានរៀល កើនឡើង១៣,៨%ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១២ ស្មើនឹង១៤,៨៣%នៃផ.ស.ស. ក្នុងនោះចំណាយថវិកាថ្នាក់ជាតិសរុបមានចំនួន ៨ ៩៤៩ ០៧៣លានរៀល កើនឡើង១៣,២% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១២ គឺស្មើនឹង ១៤,១៥%នៃផ.ស.ស. និងចំណាយថវិកាថ្នាក់ក្រោមជាតិសរុបមានចំនួន៥៦០ ៦១០លានរៀល កើនឡើង៣១% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១២ គឺស្មើនឹង០,៨៩%នៃផ.ស.ស.។ ចំណាយចរន្តថវិការដ្ឋសរុបមានចំនួន៧ ៥២៧ ១០១លានរៀល កើនឡើង១៤,៤% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១២ ស្មើនឹង១១,៩០%នៃផ.ស.ស. ក្នុងនោះចំណាយចរន្តថវិកាថ្នាក់ជាតិមានចំនួន៧ ២១២ ៥៧៣លានរៀល កើនឡើង១៣,៩% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១២ ស្មើនឹង១១,៤១%នៃផ.ស.ស. និងចំណាយចរន្តថវិកាថ្នាក់ក្រោមជាតិមានចំនួន៤៤៣ ២០៣លានរៀល កើនឡើង២៩,៣% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១២ ស្មើនឹង០,៧០%នៃផ.ស.ស.។ ចំណាយមូលធនថវិការដ្ឋសរុបមានចំនួន៤ ៩៩៩ ៩០៧លានរៀល កើនឡើង១០,៦% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១២ ស្មើនឹង ៧,៩១%នៃផ.ស.ស.។ ចំណាយចរន្តថវិកាថ្នាក់ជាតិត្រូវបានវិភាជទៅតាមវិស័យធំៗ ទាំងបួនដែលរួមមាន: (១)វិស័យសង្គមកិច្ចចំនួន៤,៣៤%នៃផ.ស.ស. កើនឡើង១២,៨% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១២ (២)វិស័យសេដ្ឋកិច្ចចំនួន០,៩៤%នៃផ.ស.ស. កើនឡើង១០% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១២ (៣)វិស័យរដ្ឋបាលទូទៅចំនួន១,៧៤%នៃផ.ស.ស. កើនឡើង១៨% ធៀបនឹង

ច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១២ និង(៤)វិស័យការពារជាតិនិងសន្តិសុខចំនួន២,៥៣%នៃផ.ស.ស. កើនឡើង១៤,៥% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១២។ ចំណាយមូលធនសរុបត្រូវបានបែងចែកជាពីរប្រភេទគឺ៖ (១)ចំណាយមូលធនដោយថវិកាជាតិមានចំនួន១ ៨៥៣ ៩០៧លានរៀល ស្មើនឹង២,៩៣%នៃផ.ស.ស. កើនឡើង១១,៥% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១២ ដែលក្នុងនោះចំណាយសម្រាប់ការទូទាត់ប្រាក់កម្ចីមានចំនួន០,៤៤%នៃផ.ស.ស. កើនឡើង១២% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១២ និង(២)ចំណាយមូលធនដោយហិរញ្ញប្បទានក្រៅប្រទេសមានចំនួន៣ ១៤៦ ០០០លានរៀល ស្មើនឹង៤,៩៧% កើនឡើង១០% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១២។

៩- *ដើម្បីបំពេញតាមគោលនយោបាយចំណាយខាងលើរាជរដ្ឋាភិបាលប្តេជ្ញាបន្តពង្រឹងនិងពង្រីកការប្រមូលចំណូលបន្ថែមទៀត ជាពិសេស ការបន្តកែលម្អគោលនយោបាយនិងរដ្ឋបាលគយនិងរដ្ឋាករ ពន្ធដារនិងចំណូលមិនមែនសារពើពន្ធ ក្នុងក្របខ័ណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលនឹងបន្តជំរុញការអនុវត្តពន្ធលើអចលនទ្រព្យ ដើម្បីជាប្រយោជន៍ដល់ថវិកាថ្នាក់ក្រោមជាតិដែលរួមមាន៣ថ្នាក់គឺរាជធានីខេត្ត ក្រុងស្រុក និងឃុំសង្កាត់។* ចំណូលក្នុងស្រុកថវិកាជាតិសរុបឆ្នាំ២០១៣ ត្រូវសម្រេចឲ្យបាន៨៩៨៧ ៧១៣លានរៀល កើនឡើង១៦,៥% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១២ ស្មើនឹង១៤,២១%នៃផ.ស.ស. ក្នុងនោះ១៣,៥៣%នៃផ.ស.ស. ជាចំណូលថវិកាថ្នាក់ជាតិ និង០,៦៨%នៃផ.ស.ស. ជាចំណូលថវិកាថ្នាក់ក្រោមជាតិ ហើយក្នុងនោះចំណូលចរន្តថវិកាជាតិសរុបមាន១៤,០៨%នៃផ.ស.ស. និងចំណូលមូលធនក្នុងប្រទេសមាន០,១៣%នៃផ.ស.ស.។ ចំណូលចរន្តថវិកាថ្នាក់ជាតិមាន១៣,៤០%នៃផ.ស.ស. បានមកពីចំណូលសារពើពន្ធចំនួន១១,៥៨%នៃផ.ស.ស. ដែលក្នុងនោះ៦,៤៣%នៃផ.ស.ស. ជាចំណូលគយនិងរដ្ឋាករ ៤,៨៣%នៃផ.ស.ស. ជាចំណូលពន្ធដារ០,៣២% ជាចំណូលសារពើពន្ធផ្សេងៗទៀតនិងបានមកពីចំណូលមិនមែនសារពើពន្ធចំនួន១,៨២%នៃផ.ស.ស.។

១០- *ដូចបានគូសបញ្ជាក់ខាងលើ សេដ្ឋកិច្ចកម្ពុជានៅមានលក្ខណៈផុយស្រួយនិងហានិភ័យខ្ពស់ ដូច្នេះដើម្បីឲ្យការអនុវត្តគោលនយោបាយនិងកម្មវិធីសកម្មភាពជាអាទិភាពដែលបានកំណត់ខាងលើអាចសម្រេចបានតាមគោលដៅប្រកបដោយភាពស័ក្តិសិទ្ធិនិងប្រសិទ្ធភាពខ្ពស់ រាជរដ្ឋាភិបាលនឹងបន្តអប្បមាទជាប្រចាំនិងដាក់ចេញនូវវិធានការទាន់ពេលវេលា ព្រមទាំងបន្តជំរុញបន្ថែមទៀតនូវការអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវកម្មវិធីកែទម្រង់លើគ្រប់វិស័យឲ្យបានកាន់តែស៊ីជម្រៅ ពិសេស ការបន្តជំរុញការអនុវត្តនូវគោលនយោបាយ កម្មវិធីអភិវឌ្ឍ និងកម្មវិធីកែទម្រង់សំខាន់ៗ និងចាំបាច់មួយចំនួនដូចជា៖*

ក.បន្តអនុវត្តគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចដ៏ត្រឹមត្រូវ គ្រប់ជ្រុងជ្រោយ និងប្រកបដោយប្រសិទ្ធភាព ជាពិសេស ការជំរុញការអភិវឌ្ឍវិស័យឯកជន ការជំរុញការពង្រឹងនិងពង្រីកវិស័យហិរញ្ញវត្ថុនិងធនាគារ ដើម្បីបង្កើតបរិយាកាសទាក់ទាញការវិនិយោគនិងបង្កើនភាពជឿទុកចិត្តលើទីផ្សារក្នុងស្រុកដែលជាកត្តាសំខាន់សម្រាប់ការសម្រេចឲ្យបាននូវកំណើនសេដ្ឋកិច្ចខ្ពស់និងប្រកបដោយចីរភាព។

ខ. បន្តអនុវត្តគោលនយោបាយហិរញ្ញវត្ថុសាធារណៈប្រកបដោយភាពម៉ឺងម៉ាត់ និងប្រុងប្រយ័ត្ន ជាពិសេស ការបន្តជំរុញការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី២ ដើម្បីបន្តពង្រឹង ***ភាពជឿទុកចិត្តបាននៃថវិកា*** និង ***បង្កើនគណនេយ្យភាពហិរញ្ញវត្ថុ*** ដើម្បីធានាបាននូវគណនេយ្យភាពនិងប្រសិទ្ធភាពក្នុងការប្រើប្រាស់ថវិកាសាធារណៈ ក្នុងគោលដៅបង្កើនភាពសក្តិសិទ្ធិនិងប្រសិទ្ធភាពក្នុងការផ្តល់សេវាសាធារណៈ។

គ. បន្តអនុវត្តគោលនយោបាយអភិវឌ្ឍវិស័យកសិកម្មនិងពិពិធកម្មសេដ្ឋកិច្ច ជាពិសេសការជំរុញផលិតកម្មស្រូវនិងការនាំចេញអង្ករ ការបង្កើនទិន្នផលនិងតម្លៃបន្ថែមលើផលិតផលកសិកម្ម ការជំរុញការអភិវឌ្ឍវិស័យកសិឧស្សាហកម្ម ការជំរុញការអភិវឌ្ឍសហគ្រាសធុនតូចនិងមធ្យមការពង្រឹងនិងពង្រីកមីក្រូហិរញ្ញវត្ថុគ្រប់ប្រភេទនិងការបង្កើនការកសាងនិងថែទាំហេដ្ឋារចនាសម្ព័ន្ធរូបវន្តនៅជនបទ ពិសេសប្រព័ន្ធស្រោចស្រព។

ឃ.បន្តអនុវត្តគោលនយោបាយគ្រប់គ្រងដីធ្លីប្រកបដោយប្រសិទ្ធភាព ជាពិសេស បន្តជំរុញការកែទម្រង់ការគ្រប់គ្រងដីធ្លី ដូចជាការបន្តជំរុញការចុះបញ្ជីដីធ្លីជាប្រព័ន្ធ ជាពិសេសបន្តជំរុញការអនុវត្តគោលនយោបាយចាស់សកម្មភាពថ្មី ការខិតខំដោះស្រាយទំនាស់ដីធ្លី ការបង្កើនប្រសិទ្ធភាពការអនុវត្តការផ្តល់ដីសម្បទានសង្គមកិច្ចនិងសេដ្ឋកិច្ច ព្រមទាំងការបង្កើនការផ្សព្វផ្សាយនិងការយល់ដឹងពីច្បាប់ភូមិបាល ដើម្បីគាំទ្រដល់វិស័យកសិកម្ម ដើម្បីឲ្យវិស័យនេះក្លាយទៅជាមូលដ្ឋានដ៏រឹងមាំនៃកំណើនសេដ្ឋកិច្ចនិងបម្រើឲ្យគោលដៅនៃការកាត់បន្ថយភាពក្រីក្រ។

ង.បន្តអនុវត្តគោលនយោបាយអភិវឌ្ឍវិស័យសង្គមកិច្ច ជាពិសេសការបន្តជំរុញនិងលើកកម្ពស់វិស័យអប់រំ និងសុខាភិបាល ស្របតាមគោលនយោបាយនិងយុទ្ធសាស្ត្រតាមវិស័យ និងគោលដៅសហស្សវត្សរ៍ដែលជាមូលដ្ឋានដ៏សំខាន់និងចាំបាច់បំផុតសម្រាប់ការកសាងធនធានមនុស្សប្រកបដោយប្រសិទ្ធភាព និងដើម្បីសម្រេចបាននូវការកាត់បន្ថយភាពក្រីក្រ ការអភិវឌ្ឍនិងវឌ្ឍនភាពសង្គម។

ច.បន្តអនុវត្តគោលនយោបាយកែទម្រង់រដ្ឋបាលសាធារណៈ ពិសេស តាមរយៈការបន្តបង្កើនការគ្រប់គ្រងនិងការអភិវឌ្ឍធនធានមន្ត្រីរាជការ ការបន្តកែលម្អប្រព័ន្ធបៀវត្សនិងលើកទឹកចិត្ត ព្រមទាំងប្រព័ន្ធត្រួតពិនិត្យនិងវាយតម្លៃសមិទ្ធកម្ម ដើម្បីបង្កើនប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈឲ្យកាន់តែប្រសើរឡើង។

ឆ.បន្តអនុវត្តគោលនយោបាយវិមជ្ឈការនិងវិសហមជ្ឈការ ជាពិសេសបន្តជំរុញការធ្វើវិមជ្ឈការនិងវិសហមជ្ឈការលើផ្នែករដ្ឋបាល បច្ចេកទេសនិងហិរញ្ញវត្ថុ ដើម្បីបង្កើនសមត្ថភាពជំនាញ ភាពជាម្ចាស់ និងការទទួលខុសត្រូវរបស់ក្រសួងស្ថាប័ន រាជធានី ខេត្ត ក្រុងស្រុកខណ្ឌ ឃុំសង្កាត់ និងអង្គភាពក្រោមឱវាទគ្រប់ជាន់ថ្នាក់ ដើម្បីគាំទ្រដល់ការអនុវត្ត ***ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ*** និង ***ច្បាប់ស្តីពីរបបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ*** ព្រមទាំងជំរុញការអនុវត្ត ***កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ***។

ជ.ក្នុងក្របខ័ណ្ឌ "**យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១១-២០២០**" រាជរដ្ឋាភិបាលនឹងបន្តពង្រឹងនិងពង្រីកប្រព័ន្ធធនាគារ វិស័យធានារ៉ាប់រង ទីផ្សារមូលបត្រនិងទីផ្សារភាគហ៊ុន ដើម្បី

បង្កើនការកៀរគរធនធានហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាព បង្កើនសក្តានុពលភាព និងកាលានុវត្តភាពដល់ការធ្វើហិរញ្ញប្បទាន ដែលនឹងក្លាយជាយន្តការទីផ្សារហិរញ្ញវត្ថុដ៏មានសារៈសំខាន់សម្រាប់ជំរុញការអភិវឌ្ឍវិស័យឯកជន ជាពិសេសការបង្កើនការវិនិយោគក្នុងស្រុក។ រាជរដ្ឋាភិបាលនឹងបង្កើនប្រសិទ្ធភាព និងចីរភាពនៃការគ្រប់គ្រងអនុបំណុលដែលជាមូលនិធិវិនិយោគនៅក្នុងវិស័យធនាគារនិងមីក្រូហិរញ្ញវត្ថុ ដើម្បីបន្តជំរុញការអភិវឌ្ឍវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា តាមរយៈការសុំការអនុញ្ញាតឲ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុធ្វើជាបញ្ញត្តិករបរធនបាលកិច្ចហិរញ្ញវត្ថុ ដើម្បីគ្រប់គ្រងនិងថែរក្សាមូលនិធិដែលជាបរធនដែលរាជរដ្ឋាភិបាលបានចុះកិច្ចព្រមព្រៀងជាមួយដៃគូអភិវឌ្ឍនិងស្ថិតនៅក្រោមការគ្រប់គ្រងរបស់គ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុ។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលក៏ស្នើសុំការអនុញ្ញាតដើម្បីបោះផ្សាយសញ្ញាបណ្ណ ដើម្បីបំពេញដើមទុនជូនក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតកម្ពុជាផងដែរ។

**ឈ.** ដោយផ្អែកលើស្ថានភាពជីវភាពប្រជាពលរដ្ឋបច្ចុប្បន្ននិងឈរលើគោលនយោបាយផ្តល់ដីធ្លីនិងកម្មសិទ្ធិជូនប្រជាជន ក្នុងគោលដៅរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ព្រមទាំងដោយប្រកាន់គោលការណ៍សមធម៌ រាជរដ្ឋាភិបាលស្នើសុំការអនុញ្ញាតបន្ធូរបន្ថយពន្ធប្រថាប់ត្រាក្នុងករណីទទួលកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនវត្ថុពីញាតិដោយសន្តតិកម្ម(មរតកពីមនុស្សស្លាប់) ឬដោយប្រទានកម្ម(អំណោយពីមនុស្សរស់)។ ដោយឡែកចំពោះការទទួលកម្មសិទ្ធិឬសិទ្ធិកាន់កាប់ដីក្នុងលក្ខណៈសម្បទានពីរាជរដ្ឋាភិបាល រាជរដ្ឋាភិបាលស្នើសុំឲ្យលើកលែងពន្ធប្រថាប់ត្រា។ មួយវិញទៀត ដើម្បីបង្កើនការគ្រប់គ្រងនិងប្រមូលពន្ធលើសកម្មភាពផ្ទេរភាគហ៊ុនរបស់ក្រុមហ៊ុនពីក្រុមហ៊ុនមួយទៅក្រុមហ៊ុនមួយទៀត ឬពីបុគ្គលមួយទៅបុគ្គលមួយទៀតនិងការចុះកិច្ចសន្យាផ្គត់ផ្គង់ទំនិញ ឬសេវាដែលប្រើប្រាស់ថវិការដ្ឋ រាជរដ្ឋាភិបាលស្នើសុំបន្ថែមនិងកែសម្រួលពន្ធប្រថាប់ត្រាចំពោះករណីទាំងនេះ។

## III. បញ្ហាប្រឈមនិងវិធានការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣

១១-*ភាពមិនប្រាកដប្រជានៃសេដ្ឋកិច្ចនិងហិរញ្ញវត្ថុពិភពលោក ពិសេសវិបត្តិបំណុលនៅអឺរ៉ុប និងភាពមិនច្បាស់លាស់នៃការងើបឡើងវិញដ៏យឺតនៃសេដ្ឋកិច្ចអាមេរិក និងពិពិធកម្មមូលដ្ឋានកំណើនសេដ្ឋកិច្ចជាមួយនឹងការរីកចម្រើននៃប្រព័ន្ធធនាគារនិងហិរញ្ញវត្ថុនៅមានកម្រិត ព្រមទាំងកំណើនតម្រូវការចំណាយពិសេសចំណាយសម្រាប់ពង្រឹងយន្តការប្រជាធិបតេយ្យគឺការបោះឆ្នោតសាកល ចំណាយសង្គមកិច្ច ចំណាយវិនិយោគសាធារណៈ និងចំណាយចាំបាច់សម្រាប់ការការពារអធិបតេយ្យនិងគ្រោះធម្មជាតិ ជាមួយនឹងកំណើនចំណូលពុំទាន់ដល់គោលដៅ០,៥%នៃផ.ស.ស. គឺជាបណ្តាបញ្ហាប្រឈមក្នុងការសម្រេចឲ្យបាននូវគោលដៅនៃគោលនយោបាយដូចបានគូសបញ្ជាក់ខាងលើ ដែលរាជរដ្ឋាភិបាលនឹងបន្តគ្រប់គ្រងនិងដាក់ចេញនូវវិធានការដោះស្រាយឲ្យបានដូចខាងក្រោម៖*

ទី១-*ភាពមិនប្រាកដប្រជានៃសេដ្ឋកិច្ចនិងហិរញ្ញវត្ថុពិភពលោក ពិសេសវិបត្តិបំណុលនៅអឺរ៉ុប និងភាពមិនច្បាស់លាស់នៃការងើបឡើងវិញដ៏យឺតនៃសេដ្ឋកិច្ចអាមេរិក ដែលបាននិងកំពុងបន្តគំរាមកំហែងដល់កំណើនសេដ្ឋកិច្ចកម្ពុជានិងចំណូលថវិកាជាតិ។* ប្រការនេះ ទាមទារឲ្យយើងនៅតែបន្តបង្កើនការអប្បមាទជាប្រចាំ និងត្រៀមលក្ខណៈជានិច្ចក្នុងការដាក់ចេញនូវវិធានការប្រកបដោយការ

ប្រុងប្រយត្ន័ខ្ពស់និងទាន់ពេលវេលា ព្រោះបញ្ហាបាត់តុល្យភាពរវាងវិស័យផលិតកម្មនិងហិរញ្ញវត្ថុ បញ្ហាកំណើនបំណុលសាធារណៈ បញ្ហាអត្រានិកម្មភាពខ្ពស់ បញ្ហាការធ្លាក់ចុះនៃតម្រូវការទីផ្សារ និងបញ្ហាអត្រាអតិផរណានៅតែជាបញ្ហាដ៏ក្តៅគគុកនៅឡើយ ហើយដែលឥទ្ធិពលទាំងនេះអាចនឹងចម្លងមកលើសេដ្ឋកិច្ចកម្ពុជាបានយ៉ាងងាយ ពិសេសតាមរយៈវិស័យដែលពឹងផ្អែកលើទីផ្សារខាងក្រៅ ដូចជាវាយនភណ្ឌ ទេសចរណ៍ និងកសិផលមួយចំនួន។

ទី២- *ពិពិធកម្មមូលដ្ឋានកំណើនសេដ្ឋកិច្ចជាមួយនឹងការរីកចម្រើននៃប្រព័ន្ធធនាគារនិងហិរញ្ញវត្ថុនៅមានកម្រិតធ្វើឲ្យសេដ្ឋកិច្ចកម្ពុជាត្រូវបន្តពឹងផ្អែកលើទីផ្សារខាងក្រៅនិងងាយរងនូវឥទ្ធិពលពីខាងក្រៅ។* មូលដ្ឋានគ្រឹះនៃកំណើននិងជាសសរទ្រូងដ៏សំខាន់នៃសេដ្ឋកិច្ចកម្ពុជា បន្ទាប់ពីវិស័យកសិកម្មគឺផ្នែកឧស្សាហកម្មកាត់ដេរ ផ្នែកសេវាកម្មទេសចរណ៍និងសំណង់ដែលកំពុងស្ថិតក្នុងដំណាក់កាលអភិវឌ្ឍ និងពុំទាន់រឹងមាំនៅឡើយ បាននិងកំពុងបន្តទទួលរងហានិភ័យពីខាងក្រៅនិងទទួលរងនូវការប្រកួតប្រជែងកាន់តែខ្លាំងឡើងជាមួយបណ្តាប្រទេសនៅក្នុងតំបន់និងនៅលើទីផ្សារអន្តរជាតិ ព្រមទាំងពុំទាន់មានសមត្ថភាពក្នុងការជំរុញទីផ្សារក្នុងស្រុកនិងកម្រិតទាបនៃផលិតភាពកម្លាំងពលកម្ម។ រីឯវិស័យកសិកម្មដែលមានប្រមាណជាង៣០%នៃផ.ស.ស. និងជាមូលដ្ឋានស្រូបយកការងារប្រមាណជាង៦០% ក៏នៅមានទិន្នផលនិងផលិតភាពទាបដែរ ហើយនៅមិនទាន់ប្រើប្រាស់ឲ្យអស់សក្តានុពលភាពនៅឡើយ ព្រមទាំងបាននិងកំពុងបន្តទទួលការគំរាមកំហែងកាន់តែខ្លាំងពីគ្រោះធម្មជាតិដោយសារបាតុភាពនៃការប្រែប្រួលអាកាសធាតុ។

ទី៣- *កំណើនតម្រូវការចំណាយកាន់តែខ្ពស់ ពិសេស ចំណាយសម្រាប់ពង្រឹងយន្តការប្រជាធិបតេយ្យគឺការបោះឆ្នោតសាកល ចំណាយសង្គមកិច្ច ចំណាយវិនិយោគសាធារណៈ និងចំណាយថែជន្យចាំបាច់សម្រាប់ការការពារអធិបតេយ្យនិងគ្រោះធម្មជាតិ ជាមួយនឹងការធ្លាក់ចុះនៃកំណើនចំណូលពិសេសចំណូលពីពន្ធនាំចូលធ្វើឲ្យការកាត់បន្ថយឱនភាពថវិកាឆ្ពោះទៅរកការរក្សាអតិរេកសាច់ប្រាក់ឡើងវិញមានការលំបាកចាប់ពីវិបត្តិសេដ្ឋកិច្ចនិងហិរញ្ញវត្ថុឆ្នាំ២០០៩មក។* ទន្ទឹមនឹងរាជរដ្ឋាភិបាលកំពុងត្រូវការបង្កើនចំណាយសង្គមកិច្ចដើម្បីបង្កើនប្រសិទ្ធភាពសេវាសាធារណៈ ពិសេសសេវាអប់រំ និងសុខាភិបាល ចំណាយកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ពិសេស ផ្លូវថ្នល់និងប្រព័ន្ធស្រោចស្រព ដើម្បីពង្រឹងនិងពង្រីកមូលដ្ឋានសេដ្ឋកិច្ចក្នុងគោលដៅកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ចំណាយបៀវត្សដើម្បីបង្កើនផលិតភាពការងារនិងធានាឲ្យមន្ត្រីរាជការស៊ីវិលនិងកងកម្លាំងប្រដាប់អាវុធមានជីវភាពសមរម្យ ចំណាយថែជន្យចាំបាច់សម្រាប់ការការពារអធិបតេយ្យនិងបូរណភាពទឹកដី ព្រមទាំងគ្រោះទឹកជំនន់ក៏បានបង្កើនសម្ពាធបន្ថែមទៀត ក្នុងពេលដែលកំណើនចំណូលកំពុងមាននិន្នាការថយចុះ ពិសេស ចំណូលគយនិងរដ្ឋាករ ដែលកម្ពុជាត្រូវកាត់បន្ថយជាបណ្តើរៗនូវពន្ធនាំចូលទៅតាមក្របខ័ណ្ឌនៃតំបន់ពាណិជ្ជកម្មសេរីអាស៊ាននិងកិច្ចព្រមព្រៀងតំបន់ពាណិជ្ជកម្មសេរី។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលបានធ្វើការកាត់បន្ថយឬទម្លាក់មកសូន្យនូវអត្រាពន្ធគយលើមុខទំនិញមួយចំនួនដើម្បីជំរុញអគ្គិសនីនីយកម្មជនបទនិងកាត់បន្ថយសម្រាប់ជួយដល់វិស័យកសិកម្មនិងសហគ្រាសធុនតូចនិងមធ្យម ព្រមទាំងផលិតកម្មបម្រើទីផ្សារក្នុងស្រុកជំនួសការនាំចូល។ ម្យ៉ាងវិញទៀត ការប្រមូលពន្ធក្នុងស្រុកមានការលំបាកនិងស្មុគស្មាញជាងការប្រមូលពន្ធនាំចូលតាមមាត់ច្រកទ្វារគឺតំបន់

និងអន្តរជាតិ ដែលទាមទារសមត្ថភាពជំនាញនិងបច្ចេកវិទ្យាខ្ពស់ និងត្រូវការអប់រំដល់អ្នកជាប់កាតព្វកិច្ចពន្ធក្នុងពេលដែលវប្បធម៌ពន្ធនៅមានកម្រិតទាបនៅឡើយ។

១២- *ដើម្បីកាត់បន្ថយ និងដោះស្រាយបណ្តាបញ្ហាប្រឈមខាងលើប្រកបដោយភាពសក្តិសិទ្ធិ ប្រសិទ្ធភាព និងមានលក្ខណៈជាប្រព័ន្ធ រាជរដ្ឋាភិបាលបាននិងកំពុងជំរុញការធ្វើពិពិធកម្មសេដ្ឋកិច្ច ពង្រឹងនិងពង្រីកទីផ្សារហិរញ្ញវត្ថុនិងប្រព័ន្ធធនាគារ ព្រមទាំងបន្តពង្រឹងការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈប្រកបដោយភាពស័ររើក។* ជាក់ស្តែង រាជរដ្ឋាភិបាលបាននិងកំពុងបន្តជំរុញការពង្រឹងនិងពង្រីកមូលដ្ឋានកំណើនសេដ្ឋកិច្ចតាមរយៈការរៀបចំគោលនយោបាយយុទ្ធសាស្ត្រកសិកម្មរយៈពេលវែងបន្តជំរុញការលើកទឹកចិត្តដល់ការវិនិយោគក្នុងវិស័យកសិកម្ម និងបន្តបង្កើនការស្តារនិងកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ពិសេសប្រព័ន្ធស្រោចស្រព ដើម្បីលើកស្ទួយផលិតកម្ម និងផលិតភាពកសិកម្ម។ រាជរដ្ឋាភិបាលក៏បានដាក់ឲ្យអនុវត្តនូវគោលនយោបាយជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ ពិសេស បានបង្កើតមូលនិធិសម្រាប់ធានាឥណទានសំដៅជំរុញការផ្តល់កម្ចីដល់ការប្រមូលទិញស្រូវតាមរយៈការធានាកម្ចីពីធនាគារពាណិជ្ជដោយក្រុមហ៊ុន និងស្ថាប័នប្រមូលទិញស្រូវ។ រាជរដ្ឋាភិបាលក៏បាននិងកំពុងបន្តជំរុញការអភិវឌ្ឍវិស័យឯកជន និងការទាក់ទាញការវិនិយោគតាមរយៈការកែលម្អបរិស្ថានវិនិយោគ បរិស្ថានសង្គម និងគុណភាពសេវាទេសចរណ៍ ដើម្បីទាក់ទាញវិនិយោគទុននិងទេសចរ។ រាជរដ្ឋាភិបាលបានរៀបចំក្របខ័ណ្ឌគតិយុត្តិមួយចំនួនដែលរួមមានច្បាប់និងលិខិតបទដ្ឋានជាច្រើនដែលជាមូលដ្ឋានគ្រឹះសម្រាប់គាំទ្រ និងផ្តល់ការលើកទឹកចិត្តដល់សកម្មភាពវិនិយោគ និងធុរកិច្ច ពិសេសវិស័យកសិកម្ម កសិឧស្សាហកម្ម ឧស្សាហកម្មធុនស្រាល និងវិស័យផលិតថាមពលអគ្គិសនី។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលក៏បានបង្កើតតំបន់សេដ្ឋកិច្ចពិសេស ដើម្បីជំរុញការធ្វើពិពិធកម្មឧស្សាហកម្មកម្ពុជាបន្ថែមលើវិស័យកម្មន្តសាល ដែលជាទស្សនាទានអភិវឌ្ឍសេដ្ឋកិច្ចរយៈពេលវែង។ លើសពីនេះ វិស័យហិរញ្ញវត្ថុនិងធនាគារក៏បាននិងកំពុងរួមចំណែកក្នុងការកៀរគរធនធាន និងជំរុញការវិនិយោគទាំងក្នុងនិងក្រៅប្រទេស ហើយដែលរាជរដ្ឋាភិបាលបាននិងកំពុងបន្តកែលម្អ ពង្រីកនិងពង្រឹងការគ្រប់គ្រង ដើម្បីបង្កើនជំនឿទុកចិត្តលើប្រព័ន្ធធនាគារដែលជាមូលដ្ឋានសំខាន់និងចាំបាច់ក្នុងការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ ពិសេសការអភិវឌ្ឍទីផ្សារមូលបត្រ។ ម្យ៉ាងវិញទៀត ដើម្បីរក្សាបានស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ហិរញ្ញវត្ថុសាធារណៈ និងតុល្យភាពថវិការាជរដ្ឋាភិបាលនឹងបន្តអនុវត្តគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចដ៏ត្រឹមត្រូវគ្រប់ជ្រុងជ្រោយ ព្រមទាំងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ និងគោលនយោបាយរូបិយវត្ថុសមស្រប និងដោយប្រុងប្រយ័ត្ន។ បន្តជំរុញការអនុវត្តកំណែទម្រង់លើគ្រប់វិស័យឲ្យកាន់តែស៊ីជម្រៅ ពិសេសកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី២ កំណែទម្រង់រដ្ឋបាលសាធារណៈ និងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍថ្នាក់ក្រោមជាតិតាមបែបប្រជាធិបតេយ្យដើម្បីបន្តកែលម្អ និងពង្រឹងការគ្រប់គ្រងចំណូល និងចំណាយ ដើម្បីបង្កើនគណនេយ្យភាព តម្លាភាព ភាពសក្តិសិទ្ធិ និងប្រសិទ្ធភាពក្នុងការប្រើប្រាស់ធនធានសាធារណៈដ៏កម្រ ដើម្បីបង្កើនភាពសក្តិសិទ្ធិនិងប្រសិទ្ធភាពក្នុងការគ្រប់គ្រង និងអភិវឌ្ឍធនធានមន្ត្រីរាជការ លើកកម្ពស់

អភិបាលកិច្ចល្អ និងប្រជាធិបតេយ្យនៅក្នុងសង្គមក្នុងគោលដៅបង្កើនប្រសិទ្ធភាពសេវាសាធារណៈឲ្យកាន់តែប្រសើរឡើង។

## IV. សេចក្តីសន្និដ្ឋាន

១៣-ថវិកាឆ្នាំ២០១៣នេះគឺពិតជាឧបករណ៍គោលនយោបាយដ៏មានសារៈសំខាន់បំផុតដើម្បីអនុញ្ញាតឲ្យរាជរដ្ឋាភិបាលបន្តអនុវត្តបញ្ចប់នូវ **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម២០០៩-២០១៣** និង**យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២** សំដៅឈានទៅសម្រេចឲ្យបាននូវ **របៀបវារៈគោលនយោបាយសង្គម-សេដ្ឋកិច្ច** នៃ **កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៤**។ ជាពិសេស ដើម្បីបន្តរក្សាស្ថិរភាពនយោបាយបន្តពង្រឹងនិងពង្រីកការអនុវត្តលទ្ធិប្រជាធិបតេយ្យ បន្តរក្សាឲ្យបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងធានាបាននូវភាពស័ក្តិសិទ្ធិនិងប្រសិទ្ធភាពខ្ពស់ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងឈានទៅសម្រេចឲ្យបាននូវគោលនយោបាយគ្រឹះខាងសេដ្ឋកិច្ចគឺ "ការធានាឲ្យបាននូវកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាពក្នុងរយៈពេលវែងមានអត្រាខ្ពស់ប្រមាណ៧%ក្នុងមួយឆ្នាំ នៅលើមូលដ្ឋានទូលាយជាងមុន និងមានសមត្ថភាពប្រកួតប្រជែងជាងមុន ក្នុងបរិការណ៍អត្រាអតិផរណាទាបក្នុងកម្រិតតួលេខមួយខ្ទង់ អត្រាប្តូរប្រាក់មានស្ថិរភាព និងមានកំណើនទុនបម្រុងជាប្រចាំ" និង "ការធានាសម្រេចឲ្យបាននូវការកាត់បន្ថយអត្រានៃភាពក្រីក្រឲ្យបានលើស១%ក្នុងមួយឆ្នាំ និងការធានាកែលម្អសូចនាករសំខាន់ៗ ក្នុងវិស័យសង្គមកិច្ច ជាពិសេសក្នុងវិស័យអប់រំ សុខាភិបាល និងសមភាពយេនឌ័រ" ព្រមទាំងឈានទៅសម្រេចបាននូវគោលដៅសហស្សវត្សរ៍កម្ពុជាទាំង៩។ ថវិកានេះ ក៏បានឆ្លុះបញ្ចាំងឲ្យឃើញផងដែរពីការខិតខំប្រឹងប្រែងនិងពុះពាររបស់រាជរដ្ឋាភិបាលក្នុងការអនុវត្តកម្មវិធីអភិវឌ្ឍ និងកំណែទម្រង់លើគ្រប់វិស័យដែលកាន់តែស៊ីជម្រៅដូចជាកម្មវិធីអភិវឌ្ឍវិស័យឯកជន និងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ កំណែទម្រង់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កំណែទម្រង់រដ្ឋបាល កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍថ្នាក់ក្រោមជាតិតាមបែបប្រជាធិបតេយ្យ កំណែទម្រង់ការគ្រប់គ្រងដីធ្លី កំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ និងកំណែទម្រង់កងកម្លាំងប្រដាប់អាវុធ ព្រមទាំងការបង្កើនអភិបាលកិច្ចល្អ និងការបង្កើនការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ដើម្បីពង្រឹងនិងពង្រីកមូលដ្ឋានសេដ្ឋកិច្ចឲ្យកាន់តែធំទូលាយនិងរឹងមាំ ព្រមទាំងដើម្បីបង្កើនភាពសក្តិសិទ្ធិនិងប្រសិទ្ធភាពសេវាសាធារណៈក្នុងការបម្រើប្រជាពលរដ្ឋឲ្យកាន់តែប្រសើរឡើងថែមទៀត។

១៤- ទន្ទឹមនឹងលទ្ធផលគួរជាទីមោទនៈ ដែលរាជរដ្ឋាភិបាលសម្រេចបានកន្លងមកគឺមិនត្រឹមតែរក្សាបាននូវស្ថិរភាពនយោបាយ ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ស្ថិរភាពហិរញ្ញវត្ថុ និងរក្សាបាននូវអធិបតេយ្យបូរណភាពទឹកដី សន្តិសុខនិងសុវត្ថិភាពសង្គម នៅក្នុងពេលនិងក្រោយពេលមានវិបត្តិកលិយុគសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសកលលោក ព្រមទាំងវិបត្តិព្រំដែនកម្ពុជាថៃ និងគ្រោះទឹកជំនន់ប៉ុណ្ណោះទេ តែថែមទាំងនាំមកនូវកេរ្តិ៍ឈ្មោះដែលកម្ពុជាត្រូវបានវាយតម្លៃថាជាប្រទេសទី១៥លើពិភពលោកដែលសម្រេចបានកំណើនសេដ្ឋកិច្ចខ្ពស់ក្នុងរយៈពេល១០ឆ្នាំចុងក្រោយ ជាប្រទេសទី៥ ក្នុងចំណោមប្រទេសកំពុងអភិវឌ្ឍ

*ដែលអាចនឹងសម្រេចបាននូវគោលដៅអភិវឌ្ឍសហស្សវត្សរ៍ និងស្ថិតក្នុងចំណាត់ថ្នាក់ទី១ នៅអាស៊ីប៉ាស៊ីហ្វិកដែលសម្រេចបាននូវវឌ្ឍនភាពល្អប្រសើរក្នុងការកែលម្អសូចនាករផ្នែកសង្គមកិច្ចកម្ពុជាអាចនឹងក្លាយទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតទាបនៅឆ្នាំ២០១៣។ ប្រការនេះ គឺពិតជាបានសបញ្ជាក់ឲ្យឃើញថាកម្ពុជាមានការវិវត្តផ្លាស់ប្តូរពីបរិមាណមកគុណភាពប្រាកដមែន។ ដូច្នេះវាក៏ទាមទារឲ្យមានការកែលម្អនិងពង្រឹងសមត្ថភាព និងការគ្រប់គ្រងស្ថាប័នឲ្យកាន់តែមានភាពសក្តិសិទ្ធិនិងប្រសិទ្ធភាពថែមទៀតនោះគឺការប្តេជ្ញាចិត្តដ៏ត្រឹមត្រូវនិងមោះមុតក្នុងការបន្តជំរុញកំណែទម្រង់លើគ្រប់វិស័យឲ្យកាន់តែស៊ីជម្រៅ ពិសេសកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការនិងកំណែទម្រង់រដ្ឋបាលសាធារណៈ*។ កំណែទម្រង់ទាំង៣នេះ គឺជាមុខព្រួញដ៏សំខាន់ក្នុងចំណោមមុខព្រួញដទៃទៀតនៃបណ្តាកម្មវិធីកែទម្រង់របស់រាជរដ្ឋាភិបាល ដែលមានវិសាលភាពគ្របដណ្តប់លើគ្រប់វិស័យនិងកាន់តែស៊ីជម្រៅ ព្រមទាំងមានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធ ហើយដែលបាននិងកំពុងរួមចំណែកជាបណ្តើរៗក្នុងការកែលម្អនិងបង្កើនភាពសក្តិសិទ្ធិនិងប្រសិទ្ធភាពនៃរចនាសម្ព័ន្ធស្ថាប័ននិងប្រពន្ធ័គ្រប់គ្រងរដ្ឋបាលសាធារណៈទាំងមូល។ ជោគជ័យនៃកំណែទម្រង់ទាំងនេះ គឺជាចំណែកដ៏សំខាន់នៃកត្តាកំណត់ជោគជ័យក្នុងការអនុវត្ត **យុទ្ធសាស្រ្តចតុកោណដំណាក់កាលទី២** និង **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម២០០៩-២០១៣** ដើម្បី*ជំរុញកំណើនបង្កើតការងារ ធានាសមធម៌* និង*ប្រសិទ្ធភាព* ដែលជាមូលដ្ឋានចាំបាច់សម្រាប់ឈានទៅសម្រេចឲ្យបាននូវការកាត់បន្ថយភាពក្រីក្រ និងសម្រេចបានតាមគោលដៅសហស្សវត្សរ៍កម្ពុជាពិសេសគឺដើម្បីការអភិវឌ្ឍ វឌ្ឍនភាព និងវិបុលភាព ព្រមទាំងភាពសុខដុមរមនានិងសុភមង្គលរបស់ប្រជាជនកម្ពុជាទាំងមូល។ ដូច្នេះយើងអាចប្រសិទ្ធិនាមថវិកាឆ្នាំ២០១៣ថាជាថវិកាសម្រាប់ "*បន្តពង្រឹងនិងពង្រីកការអនុវត្តលទ្ធិប្រជាធិបតេយ្យ មូលដ្ឋានសេដ្ឋកិច្ចនិងវឌ្ឍនភាពសង្គមប្រកបដោយគុណភាពតាមរយៈការបន្តរក្សាស្ថិរភាពនយោបាយ ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ស្ថិរភាពហិរញ្ញវត្ថុសាធារណៈ ព្រមទាំងបន្តជំរុញការអភិវឌ្ឍវិស័យគន្លឹះ ពិសេសវិស័យកសិកម្ម កសិឧស្សាហកម្ម ឧស្សាហកម្មធុនស្រាលនិងទេសចរណ៍ និងការអនុវត្តកម្មវិធីកំណែទម្រង់លើគ្រប់វិស័យឲ្យកាន់តែស៊ីជម្រៅ*។ អាទិភាពចំណាយនៃថវិកាឆ្នាំ២០១៣ បានឆ្លុះបញ្ចាំងឲ្យឃើញយ៉ាងប្រត្យក្សនូវនិយមន័យខាងលើ ជាពិសេស វិស័យអប់រំ សុខាភិបាល កសិកម្ម កសិឧស្សាហកម្ម ធារាសាស្ត្រ អភិវឌ្ឍន៍ជនបទ ការបន្តពង្រឹងនិងពង្រីកហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដូចជាផ្លូវថ្នល់ ស្ពាន ទំនប់ ប្រឡាយ ប្រព័ន្ធស្រោចស្រព និងអគ្គិសនីដែលនៅតែជាមុខព្រួញសំខាន់ចាំបាច់និងជាអាទិភាពរបស់រាជរដ្ឋាភិបាល។

១៥- *ជាចុងក្រោយនិងកាន់តែសំខាន់ជាងគេទៅទៀតនោះគឺកត្តាធនធានមនុស្សប្រកបដោយសមត្ថភាព និងគោលនយោបាយប្រកបដោយចក្ខុវិស័យត្រឹមត្រូវនិងច្បាស់លាស់។* ការកសាងនិងការអភិវឌ្ឍធនធានមនុស្ស ពិសេសការពង្រឹងសមត្ថភាពនិងបង្កើនផលិតភាពការងារព្រមទាំងការផ្តល់ប្រាក់បៀវត្សសមស្របគឺជាកត្តាសំខាន់និងចាំបាច់មិនអាចខ្វះបានដើម្បីធានាប្រសិទ្ធភាពនិងស្ថិរភាពការងារ។ រាជរដ្ឋាភិបាលនៅតែបន្តអនុវត្តគោលនយោបាយដំឡើងប្រាក់បៀវត្សមូលដ្ឋានជូនមន្ត្រីរាជការស៊ីវិលនិងកងកម្លាំងប្រដាប់អាវុធ២០% បន្ថែមទៀតនៅក្នុងឆ្នាំ២០១៣នេះ ហើយក៏បាននិងកំពុងបន្ត

ពង្រឹងការអនុវត្តបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិលនិងបេឡាជាតិសន្តិសុខអតីតយុទ្ធជន ដើម្បីបន្តកែលម្អការអនុវត្តប្រាក់សោធននិវត្តន៍និងប្រាក់ឧបត្ថម្ភផ្សេងៗឲ្យកាន់តែប្រសើរឡើង។ ដូច្នេះ រាជរដ្ឋាភិបាលយកចិត្តទុកដាក់ខ្ពស់ដល់ការលើកកម្ពស់កម្រិតជីវភាពមន្ត្រីរាជការស៊ីវិលនិងកងកម្លាំងប្រដាប់អាវុធទាំងនៅក្នុងពេលបំពេញការងារ ទាំងនៅពេលចូលនិវត្តន៍ ឬបាត់បង់សម្បទាវិជ្ជាជីវៈ ឬបាត់បង់សមត្ថភាពការងារ ឬបាត់បង់សមត្ថភាពពលកម្ម ឬជនពិការដែលជាអតីតយុទ្ធជន ព្រមទាំងគ្រួសារជនពលីដែលមានគុណបំណាច់ចំពោះជាតិមាតុភូមិថែមទៀតផង ដើម្បីជានាលើកកម្ពស់សំណាញ់សុវត្ថិភាពសង្គម។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលមានគោលនយោបាយនិងយុទ្ធសាស្ត្រប្រកបដោយចក្ខុវិស័យដ៏ត្រឹមត្រូវនិងច្បាស់លាស់មានការដឹកនាំដ៏ឈ្លាសវៃនិងម៉ឺងម៉ាត់ មានរចនាសម្ព័ន្ធគ្រប់គ្រងប្រកបដោយភាពសក្តិសិទ្ធិនិងប្រសិទ្ធភាព ព្រមទាំងបាននិងកំពុងអនុវត្តកម្មវិធីកែទម្រង់សមស្របនិងទាន់ពេលវេលាដែលជាប្រការសំខាន់និងចាំបាច់មិនអាចខ្វះបានក្នុងការសម្រេចជោគជ័យទៅតាមគោលដៅនៃ **យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២** ក៏ដូចជា **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម២០០៩-២០១៣** ដើម្បី*ជំរុញកំណើន បង្កើតការងារ ជានាសមធម៌* និង*ប្រសិទ្ធភាព* នៅកម្ពុជា ដែលជា ***របៀបវារៈគោលនយោបាយសង្គម-សេដ្ឋកិច្ច*** *នៃ* ***កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៤***។

សេចក្តីដូចបានជម្រាបជូនខាងលើនេះ សូមរដ្ឋសភាមេត្តាពិនិត្យនិងអនុម័តសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣នេះ ដោយចាត់ទុកជាការប្រញាប់ ដោយក្តីអនុគ្រោះ។

រាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែ [illegible] ឆ្នាំ២០១២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**